# ការសម្ភាសរបស់អ៊ុំ ចាន់ សុផល

កៈ អ្នកសម្ភាសឈ្មោះ សួន រាម ខៈអ្នកត្រូវគេសម្ភាស ឈ្មោះចាន់ សុផល

កៈ ជម្រាបសួរអ៊ុំខ្ញុំឈ្មោះសួន រាម។ ខ្ញុំមកពីសាកលBYUជាគម្រោងដើម្បីឱ្យយើងផ្សាព្វផ្សាយប្រវត្តិរូបរបស់ប្រជាជនខ្មែរយើង ដោយសារថាប្រទេសគាត់បានដឹងពីប្រវត្តសាស្រ្ត ប្រវត្តិរូបរបស់ឪពុកម្តាយគេមានន័យថានៅស្រុកខ្មែរ អត់មានដឹងឮពីប្រវត្តិសាស្រ្តរបស់ឪពុកម្តាយគេទេ។ អញ្ចឹងគាត់មានគម្រោងហ្នឹងមួយ ដើម្បីស្វែងរកម្តងទៀតដូចជាសិស្សនៅ សាកលវិទ្យាល័យBYU។ គាត់បានដឹងពីប្រវត្តិរូបរបស់ខ្មែរចាប់អារម្មណ៍ ដើម្បីគាត់មកលេងនៅស្រុកខ្មែរយើង អញ្ចឹងសូមស្គាល់ឈ្មោះអ៊ុំឈ្មោះអីគេដែរ?

ខៈ ខ្ញុំឈ្មោះចាន់ សុផល។

កៈ ឥឡូវអ៊ុំអាយុប៉ុន្មានហើយ?

ខៈ ៦៧ហើយ។

កៈ ៦៧នៅទីនេះគេហៅភូមិ?

ខៈ ភូមិកម្មករ។

កៈ ស្រុកអីគេដែរ?

ខៈ ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។

កៈ អ៊ុំក្រុមគ្រួសាររបស់អ៊ុំមានគ្នាចំនួនប៉ុន្មាននាក់ដែរ?

ខៈ មានគ្នាចំនួន៩នាក់ សុទ្ធតែក្មេងកំព្រា។ ខ្ញុំជីដូនចិញ្ចឹមចៅឱ្យរៀនសូត្រ សព្វថ្ងៃហ្នឹងហើយជីវភាព ខ្ញុំដើរកោសខ្យល់ឱ្យគេទៅហើយ បានលុយមកគ្រាន់តែឱ្យចៅទៅរៀនគ្មានបានធ្វើការអីធំដុំនឹងគេទេ។ ជីវិតខ្ញុំដូចថាពីដើមមកក៏កម្សត់ដែរ
ពីដើមមកក៏ម៉ែឪមានភាពក្រីក្រឪពុកម្តាយឈឺ។ ខ្ញុំនៅវ័យ១៣ឆ្នាំ
ធ្វើស្រែធ្វើចម្ការចិញ្ចឹមម៉ែឪទៅដល់ជំនាន់៧៥ ក៏បែកពី ម៉ែឪទៀត បែបរហូតដល់ជំនាន់ ប៉ុលពតវេទនាហ្នឹង។ អាពតមួយដងទៀត ដល់ឥឡូវចប់ ជំនាន់ហ្នឹងហើយ

ចូលវ័យសព្វថ្ងៃវ័យចិញ្ចឹមចៅខ្លះ មានម៉ែខ្លះមានឪពុកទៅចេះតែតស៊ូទៅ។ ហេតុតែជីវិតហ្នឹងរស់ដូចថាជីវិតសាបសូន្យទៅអាណិតតែចៅទេ គ្មានអីសព្វថ្ងៃនេះឱ្យតែបានចម្លងចៅឱ្យរួចបានរៀនសូត្រខ្លះ បានរៀនត្រឹមថ្នាក់ទី៥ ទី៦ខ្លះ ចំណាង (រកលុយដើម្បីឱ្យចៅ រៀន) ចៅតាំងពីតូច ហើយឥឡូវរៀនបាក់ឌុប ហើយឥឡូវធ្លាក់បាក់ឌុបទៀតគ្មានការងារអី ធ្វើទេ។បើយើងធ្លាក់បាក់ឌុបការលំបាកក្នុងគ្រួសារចេះ តែមានហើយគេអ្នកមាន ចេះតែមាន ហើយខ្ញុំភាពក្រីក្រចេះតែក្រីក្រងើបវាមិនរួច។ យើងបន្ទោសថាយើងមិនរកមិនក្រចុះ  បើរកណា បើចៅនៅតូចៗ ហើយម៉ែឪគេខ្លះព្រាត់ប្រាសគ្នាអស់ខ្លះ ស្លាប់ខ្លះរស់ដល់ជីវិតរាល់ថ្ងៃហ្នឹងគឺជីវិតចិញ្ចឹមចៅទេ។

ក៖ អញ្ចឹងចង់ដឹង......

ខ៖ ឈ្មោះពិតប្រាកដរបស់ខ្ញុំឈ្មោះក្នុងបញ្ជីជាតិ។ ចាស! ឈ្មោះក្នុងអត្តសញ្ញាណប័ត្រខ្ញុំឈ្មោះចាន់ សុផល។

ក៖ អញ្ចឹងអ៊ុំមានឈ្មោះហៅក្រៅទេ?

ខ៖ ហៅក្រៅមានខ្លះគេហៅខ្ញុំថាយ៉េត ខ្លះគេហៅខ្ញុំថាយីដក។ប៉ុន្តែឈ្មោះក្នុងបញ្ជីជាតិខ្ញុំឈ្មោះ ចាន់ សុផល ប៉ុន្តែអ្នកប្រជាជនភូមិផងរបងជាមួយគ្នាគេចេះតែហៅយើង លេងហើយយីយ៉េតហ្នឹងក៏ពីកំណើតម៉ែដាក់ឱ្យដែរ។

ក៖ បាទ!

ខ៖ ប៉ុន្តែមិនដែលមានពាក្យហ្នឹងទេ ប្រើតែពាក្យ ចាន់ សុផលដែលធ្វើសំបុត្រកំណើតអីណោះ។

ក៖ ចុះឈ្មោះអីកុមារ?

ខ៖ ឈ្មោះពីកុមានៅភូមិគេហៅយ៉េតដល់ពេលធំពេញវ័យ សព្វថ្ងៃនេះគេដាក់ ចាន់ សុផល តាមបញ្ជីជាតិ។

ក៖ ចង់ដឹងថាក្រៅពីភាសាខ្មែរអ៊ុំអាចនិយាយភាសាអីផ្សេងទៀតទេ?

ខ៖ អត់ចេះទេ! ភាសាខ្មែរមើលតែអក្សរមិនដាច់ផងហ្នឹង ឃ្លាខ្លះមើលមិនយល់ក៏រំលងចោលទៅ។

ក៖ បាទ!

ខ៖ កាលនៅពីតូចគ្មានបានរៀន សូត្រអីម៉ែឪក្រីក្រដល់ហើយរៀនអក្ខរកម្មធម្មតាហ្នឹងដល់ពេលនេះ ទៅស្រុកទេសរត់ចុះរត់ឡើងក៏ (ប្រទេសមានសង្គ្រាម) បែកបាក់គ្នាអស់រហូតដល់សព្វថ្ងៃនេះ មិនដែលជួបបងប្អូនណា ឥឡូវមានម្តាយមីងមួយស្រុកកំណើតសព្វថ្ងៃហ្នឹង។ គាត់អាយុ៧២ហើយក្មួយនេះ៦២ហើយ។

ក៖ ចុះអ៊ុំចេះសរសេរភាសាខ្មែរទេ?

ខ៖ ខ្ញុំមិនចេះសរសេរ ចេះតែអាន អានដូចថាយើងមើលបានខ្លះ។ បើពីដើមខ្ញុំសរសេរកើតតើ ប៉ុន្តែចាប់ពីជំនាន់ ប៉ុល ពត មកខ្ញុំសរសេរលេងកើតអញ្ចឹងចាំតែមើលទេ។ ខ្ញុំមើលទៅដូចថាខ្ញុំអានកាសែតអីអញ្ចឹងទៅមួយឃ្លាៗ តែបើឱ្យសរសេរខ្ញុំមិនចេះសរសេរលេខខ្ញុំស្គាល់ ប៉ុន្តែខ្ញុំសរសេរមិនកើត។

ក៖ តើអ៊ុំដឹងថាអ៊ុំកើតនៅណាទេ?

ខ៖ ខ្ញុំកើតនៅស្រុកមោង ភូមិអូរឈើទី។

ក៖ អញ្ចឹងអ៊ុំអាយុប៉ុន្មានហើយ?

ខ៖ ៦៧!

ក៖ កើតឆ្នាំណា?

ខ៖ បើនិយាយពីឆ្នាំវិញកើតឆ្នាំនិយាយាមអត្តសញ្ញណបត្ររបស់យើង១៩៥២។

ក៖ អញ្ចឹងអ៊ុំមានចាំថ្ងៃអ៊ុំរៀបការទេ?

ខ៖ ខ្ញុំរៀនកាលពីឆ្នាំ១៩៦៨។

ក៖ ចុះពីណារៀបការ?

ខ៖ ឪពុកម្តាយខ្ញុំរៀបឱ្យ។

កៈ តើអ៊ុំអាចប្រាប់បានទេអំពីការជួបគ្នាដំបូង។

ខៈ ជួបគ្នាដំបូងដូចថា យើងទៅនៅស្រុកគេអញ្ចឹងទៅឃើញ យើងទៅព្រោះយើង ទៅនៅ ជាមួយបងដល់យើងមានវ័យអាយុ១៦ឆ្នាំ តែស្តីដណ្តឹងតាមរយៈ ចាស់ៗអញ្ចឹងណា៎ អញ្ចឹងខ្ញុំការនៅឆ្នាំ១៩៦៧។ ឆ្នាំ១៩៦៩ ខ្ញុំមានកូនប្រុសមួយចូលដល់ឆ្នាំ១៩៧០ខ្ញុំមានកូនពីរហើយ។

កៈ តើមានបណ្តាការទេ?

ខៈ បណ្តាការមាន ដូចថាយើងចាត់ចែងទៅចាត់អស់ទៅ (ឱ្យថ្លៃម្ហូប ឬផ្សេងៗ)។ ស្រុកយើងកាលអាពត កាលស្រុកកើតសង្គ្រាមគ្មានសល់អីទេ សូម្បីតែរូបថត សល់រូបមួយដែរកាលណោះ ធ្វើកាតយើងទុកក្នុងហោប៉ាវ ចេះបានជាប់មួយហ្នឹងឯង។
រូបថតគាត់រឿងសំបុតអាពាហ៍ពិពាហ៍យើង ធ្វើតាំងពីឆ្នាំណោះមក
មិនដឹងទៅណាអស់ទៅបាត់អស់ហើយ ម៉ែឪស្លាប់អស់ហើយ
ខាងម៉ែក្មេកក៏ស្លាប់អញ្ចឹងទៅបាត់អស់គ្មានអស់អីទេ។ ពីដើមមកយើងនៅ
ជាមួយម៉ែឪចំនួនកូនស្រី៦នាក់ ប្រុស២។ ប៉ុន្តែស្លាប់អស់ហើយនៅតែបងស្រីមួយ បីនាក់ទៀតស្លាប់អស់ហើយ។

កៈ អ៊ុំជាកូនទីប៉ុន្មាន?

ខៈ កូនទី២។ បងស្រីខ្ញុំគាត់នៅសព្វថ្ងៃគាត់បងទី១ បន្ទាប់មកខ្ញុំទី២ ទី៣ដល់ទី៦ស្លាប់ អស់ហើយ។ ឥឡូវដូចថានៅរស់នៅជាមួយកូនអញ្ចឹងណា៎ មើលកូនមើលចៅអញ្ចឹងយើងនៅផ្ទះ គេរកស៊ីចិញ្ចឹមកូនចិញ្ចឹមចៅទៅអ្នកណាអត់ម៉ែឪខ្ញុំអ្នកមើលអញ្ចឹងទៅ។

កៈ ថ្ងៃខែកំណើតរបស់ឪពុកម្តាយរបស់អ៊ុំមានចាំទេ?

ខៈ អត់ចាំ!

កៈ បាទ! យូរហើយ។

ខៈ យូរហើយ ខ្ញុំមិនអាចចាំសំបុត្រកំណើតរបស់គាត់ទេ ដឹងតែចាំឈ្មោះគាត់។

កៈ បាទ! ឈ្មោះអីគេអ៊ុំ?

ខៈ ឪពុកខ្ញុំឈ្មោះ ញុល ចាន់។

កះ បាទ! ម្ដាយអ៊ុំ។

ខះ ម្ដាយខ្ញុំឈ្មោះនង វ៉ែម។

កះ ធ្វើស្រែ?

ខះ ចាំស! ធ្វើស្រែនៅស្រុកមោង ភូមិហូរវែង។

កះ ចង់សួរទៀតអ៊ុំមានចាំថ្ងៃខែកំណើតរបស់ជីដូនជីតាក៏អត់ចាំដែរ?

ខះ អត់ចាំ! ជីដូនដឹងតែស្គាល់ឈ្មោះគាត់ ប៉ុន្តែយើងមិនដឹងគាត់ឆ្នាំណាអីឆ្នាំណាយើងមិនដឹង។

កះ បាទ!

ខះ ដឹងថាខាងម៉ែខ្ញុំឈ្មោះ យី ហង្ស។

កះ បាទ!

ខះ ហើយខាងពុកខ្ញុំឈ្មោះ យី ដែង និង តា ញុល។

កះ បាទ!

ខះ ចាំស!

កះ ចុះកន្លែងកើតរបស់គាត់អត់មានចាំថានៅកន្លែងណា?

ខះ គាត់កើតនៅស្រុកហ្នឹងម៉ង។

កះ ស្រុកអីគេអ៊ុំ?

ខះ ស្រុកនៅភូមិអូរវែងហ្នឹងម៉ង ពីដើមមកគាត់រស់នៅទឹកដីហ្នឹង។

កះ ពេលណាដែរ?

ខះ ពេលណាម៉េច?

កះ សុំទោសនៅពេលណាដែលអ៊ុំមានចាំថានៅពេលណាដែលគាត់ចាប់កំណើត?

ខះ ស្រុកគាត់នៅហ្នឹងហើយ។

កៈ បាទ!

ខៈ ស្រុកគាត់នៅស្រុកហូរវែងហ្នឹង។

កៈ បាទ!

ខៈ គាត់បានប្ដីប្រពន្ធគាត់ក៏នៅអូរវែងហ្នឹងគាត់នៅហ្នឹងម៉ង។

កៈ អញ្ចឹងឪពុកម្ដាយអ៊ុំនៅហ្នឹងទាំងអស់?

ខៈ ចា៎ស! នៅហ្នឹងទាំងអស់គ្នា។

កៈ នៅប្រទេសកម្ពុជា?

ខៈ ចា៎ស!

កៈ មានចាំខេត្តណាទេ?

ខៈ ខេត្តបាត់ដំបងយើង ភូមិអូរវែង ឃុំខ្ចូចអង្គាជី ស្រុកមោងឫស្សី ខេត្តបាត់ដំបង។

កៈ បាទ!

ខៈ ចា៎ស!

កៈ អត់មានរឿងអីផ្សេងទៀត ក្រៅពីរឿងរ៉ាវហ្នឹងអត់មានចាំអីទៀត១៩៧១?

ខៈ ១៩៧១ស្រុកកើតសង្គ្រាមហើយហ្នឹង។

កៈ បាទ!

ខៈ ដូចថាសង្គ្រាមហ្នឹង យើងបើនិយាយទៅវាកម្សត់រឿងសង្គ្រាមហ្នឹងណា៎ រត់ណាមួយយន្តហោះទម្លាក់អីអញ្ចឹងទៅមិនបាត់និយាយទេព្រោះថាគេដឹងហើយ។

កៈ បាទ! អ៊ុំអាចរៀបរាប់អ្វីដែលអ៊ុំចាំទាំងពីកុមារីក៏ឆ្លងគាត់អីគេខ្លះនៅឆ្នាំ១៩៥០ ១៩៦០ ១៩៧០មានចាំអីទៀតទេ?

ខៈ ឆ្នាំ១៩៥០-១៩៦០ យើងនៅវ័យដូចថា១៣ឆ្នាំអញ្ចឹងណា៎។

កៈ បាទ!

ខ៖ យើងនៅជាមួយឪពុកម្ដាយ តាមឪពុកម្ដាយរហូតបម្រើឪពុកម្ដាយរហូតអញ្ចឹងទៅ ដល់ពេលវ័យយើងមានប្ដី យើងបែកពីឪពុកម្ដាយមកដូចថាឃ្លាតឆ្ងាយតាមស្រុកភូមិ នៅខេត្តគេអញ្ចឹងទៅ។

ក៖ បាទ!

ខ៖ នៅជំនាន់យើង១៩៧៥នេះចេញមក យើងបែកម៉ែឪពីឆ្នាំ១៩៧៥ រហូតដល់ជំនាន់ ប៉ុល ពត ហ្នឹង។

ក៖ បាទ!

ខ៖ បានបែកគ្នាស្លាប់អស់ហើយនៅតែខ្ញុំបងប្អូន២នាក់ហ្នឹងឯង។

ក៖ បាទ! អញ្ចឹងសូមអរគុណច្រើនដែលបានឱ្យ ខ្ញុំសម្ភាសថ្ងៃនេះហើយ តើខ្ញុំអាចសុំរូបអ៊ុំបានទេ?

ខ៖ រូបបានតើ។

ក៖ បាទ! អរគុណច្រើនអ៊ុំជម្រាបលា។

ខ៖ ចាំស!

ក៖ អរគុណច្រើន៕